ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥

# សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៤

នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ដូចខាងក្រោម៖ មនុស្សឃាតដោយចេតនា ជាការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅទីកន្លែងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខទួលបេង និងមន្ទីរសន្តិសុខវត្តអូរត្រកួន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត(ដូចជា ស្ថានភាពអមនុស្សធម៌នៃការឃុំឃាំង)នៅទីកន្លែងសម្លាប់មនុស្សគោកព្រីង និងមន្ទីរសន្តិសុខទួលបេង ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត (ដូចជាស្ថានភាពអមនុស្សធម៌នៃការឃុំឃាំង)នៅមន្ទីរសុខវត្តអូរត្រកួន។

ដោយសារការដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទចោទប្រកាន់ទាំងនេះ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អនុញ្ញាតឲ្យ អោ អាន តាមរយៈមេធាវីរបស់គាត់ មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរ ដូច្នេះនឹងជួយបង្កើនល្បឿនដំណើរការស៊ើបសួរ។ ការធ្វើដូច្នេះនឹងអនុញ្ញាតឲ្យកិច្ចស៊ើបសួរ បន្តដំណើរការទៅមុខ ដោយគោរពសិទ្ធិរបស់ភាគីទាំងអស់បានពេញលេញ និងអាចបញ្ចប់កិច្ចស៊ើបសួរក្នុងចិរវេលាសមស្រប ហើយនឹងចេញដីកាដំណោះស្រាយ។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*


លោក ឡាស អូលសិន
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh